មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

## ទេចារណកថាព័ត៌មានរបស់ម.ស.ម.ក.

ភ្នំពេញ ថ្ងៃទី១៤ ធ្នូ ឆ្នាំ២០១២

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសូមសាទរសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការស្នើសុំបញ្ឈប់ការរើសអើងលើក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក)សូមស្វាគមន៍ចំពោះការគូសសម្គាល់របស់នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន នាថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១២ ជុំវិញការជម្រុញពលរដ្ឋគ្រប់រូបអោយបញ្ឈប់ការរើសអើងទៅលើក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ។ ការគូសសម្គាល់របស់សម្តេចនាយករដ្ឋមន្ត្រី បង្ហាញថារដ្ឋាភិបាលកម្ពុជាបានជ្រាប និងទទួលស្គាល់បញ្ហានិងការបារម្ភរបស់សង្គមស៊ីវិលចំពោះការរើសអើងទៅលើក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទលើគ្រប់វិស័យក្នុងសង្គមកម្ពុជា។ ម.ស.ម.ក. សង្ឃឹមថាការទទួលស្គាល់ជាសាធារណៈរបស់សម្តេចចំពោះបញ្ហានេះនឹងធ្វើអោយមានការកើនឡើងនូវការទទួលស្គាល់ជាសាធារណៈ និងកាត់បន្ថយ ការរើសអើងចំពោះសហគមន៍ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទទូទាំងកម្ពុជា។

**អ្នកសម្របសម្រួលគំរោងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក ថេង ណាន អធិប្បាយថា៖**

*"ការស្នើសុំឲ្យបញ្ឈប់ការរើសអើងទៅលើក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាការបោះជំហ៊ានដ៏គួរឲ្យស្វាគមន៍ក្នុងទិសដៅដ៏ត្រឹមត្រូវ។ ខ្ញុំសង្ឃឹមថាអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីនឹងត្រូវអនុវត្តន៍តាមរយៈជំហានជាក់លាក់របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជម្រុញអោយប្រសើរឡើងនូវស្ថានភាពរបស់ក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់*

*ទាំងពីរភេទ និងអ្នកប្តូរភេទ និងដែលកំពុងបន្តប្រឈមការរើសអើងក្នុងសហគមន៍ នៅកន្លែងធ្វើការ សេវាកម្មសុខភាព និងរាល់ផ្នែកដទៃទៀតក្នុងសង្គមកម្ពុជា។*

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងលោកចេងណានតាមរយៈទូរស័ព្ទ+៨៥៥(០)១២៤៨៨៨៩៨ឬផ្ញើអ៊ីម៉ែលមកកាន់chamnan@cchrcambodia.org ឬ កញ្ញា ហ្សូលីយ៉េតរ៉ូស្សឡូត ជាអ្នកប្រឹក្សា ម.ស.ម.ក តាមរយៈទូរស័ព្ទ+៨៥៥(០) ១៥៣៥០៦២០ឬ អ៊ីម៉ែលមកកាន់julietterousselot@cchrcambodia.org**

<u>បណ្ណាធិការ</u>

ម.ស.ម.កត្រូវបានបង្កើតឡើងនៅក្នុងខែវិច្ឆិកាឆ្នាំ២០០២ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.កគឺជាសមាជិករបស់ដៃគូអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អ៊ីហ្វិក) ដែលជាបណ្តាញសកលក្នុងការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជាwww.sithi.orgទទួលបានរង្វាន់ប្រចាំឆ្នាំ២០១១របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យាក្នុងចំណាត់ថ្នាក់នៃសិទ្ធិនិងសេរីភាព។